**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
លេខ: ១៨ សសរ.

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួង ដោះស្រាយគោលនយោបាយដីធ្លី សម្រាប់ការអភិវឌ្ឍអាកាសយានដ្ឋានអន្តរជាតិកងកេង និងហេដ្ឋារចនាសម្ព័ន្ធចំណុះក្រុងព្រះសីហនុ

### ឧបនាយករដ្ឋមន្ត្រី
### រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតរដ្ឋលេខាធិការអាកាសចរស៊ីវិល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១២ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ២៩ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការការធ្វើចំណាត់ថ្នាក់ជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ បរិវេណដីនៅក្រុងព្រះសីហនុ សម្រាប់ការអភិវឌ្ឍអាកាសយានដ្ឋានអន្តរជាតិកងកេង និងហេដ្ឋារចនាសម្ព័ន្ធចំណុះ
- យោងតាមតម្រូវការចាំបាច់

## ស ម្រេ ច

**ប្រការ ១ :** បង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីដោះស្រាយសម្របសម្រួល ជាមួយប្រជាពលរដ្ឋជាម្ចាស់កម្មសិទ្ធិ ឬភោគីនៃដីឡូតិ៍ ដែលស្ថិតក្នុងបរិវេណសម្រាប់គម្រោងការអភិវឌ្ឍអាកាសយានដ្ឋានអន្តរជាតិកងកេង និងហេដ្ឋារចនាសម្ព័ន្ធចំណុះក្រុងព្រះសីហនុ ដែលមានសមាសភាពដូចខាងក្រោម :

| | | | | |
|---|---|---|---|---|
| ១. | ឯកឧត្តម | **សេង លឹមនៅ** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២. | ឯកឧត្តម | **ញាណ ឡេង** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣. | ឯកឧត្តម | **ឆា សុផ្ហា** | អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | អនុប្រធាន |
| ៤. | ឯកឧត្តម | **សយ សុខាន់** | អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ៥. | ឯកឧត្តម | **ឆា ដុំច** | អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ៦. | ឯកឧត្តម | **សាយ ហាក់** | អភិបាលក្រុងព្រះសីហនុ | សមាជិក |
| ៧. | ឯកឧត្តម | **ឌុច ទំនឹត្ង** | អគ្គនាយករៀបចំដែនដី និងនគរូបនីយកម្ម នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៨. | ឯកឧត្តម | **លឹម ទាន់** | អគ្គនាយកសុរិយោដី និងភូមិសាស្ត្រ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៩. | លោក | **ដែង សុទិដ្ឋារ៉ា** | អគ្គនាយករងសាធារណការ និងដឹកជញ្ជូន នៃក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១០. | លោក | **គីតរ៉េត សំរេច** | ជំនួយការឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន** | សមាជិក |
| ១១. | លោក | **នេត មុន្នី** | ប្រធាននាយកដ្ឋានទ្រព្យរដ្ឋ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១២. | លោក | **សូ សុខ** | ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ក្រុងព្រះសីហនុ | សមាជិក |
| ១៣. | លោក | **បាន សារុំ** | អភិបាលខណ្ឌព្រៃនប់ | សមាជិក |
| ១៤. | លោក | **ទ្រី សុផល** | ប្រធានភូមិបាល | សមាជិក |
| ១៥. | លោក | **ចាន់ រិទ្ធិ** | មេឃុំរាម | សមាជិក |
| ១៦. | លោក | **ស្ងួន ឈុំ** | មេឃុំបិតត្រាំង | សមាជិក |

**ប្រការ ២** : គណៈកម្មការនេះមានភារកិច្ច :

- ធ្វើជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការសម្របសម្រួល និងដោះស្រាយគោលនយោបាយដីធ្លីជាមួយប្រជាពលរដ្ឋដែលជាម្ចាស់កម្មសិទ្ធិ ឬភោគីនៃដីធ្លីដែលស្ថិតនៅក្នុងគម្រោងសម្រាប់ការអភិវឌ្ឍអាកាសយានដ្ឋានអន្តរជាតិកងកេង និងហេដ្ឋារចនាសម្ព័ន្ធចំណុះក្រុងព្រះសីហនុ
- ចុះទៅពិនិត្យដល់ទីកន្លែង និងធ្វើស្ថិតិលើផលប៉ះពាល់ដីធ្លីប្រជាពលរដ្ឋ ដែលជាម្ចាស់កម្មសិទ្ធិ ឬភោគីដែលស្ថិតនៅក្នុងគម្រោងអភិវឌ្ឍន៍នេះ
- ធ្វើការវាយតម្លៃឱ្យបានសមស្រប ដើម្បីមានមូលដ្ឋានដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេចនូវថវិកាសម្រាប់ដោះស្រាយជាគោលនយោបាយជូនប្រជាពលរដ្ឋ
- ធ្វើរបាយការណ៍អំពីលទ្ធផលការងារតាមជំហាន១ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច ។

**ប្រការ ៣** : ថវិកាគោលនយោបាយសម្រាប់ដោះស្រាយសម្របសម្រួលផ្តល់ជូនប្រជាពលរដ្ឋ ដែលត្រូវចាកចេញពីបរិវេណគម្រោងអាកាសយានដ្ឋាន និងបណ្តាសោហ៊ុយចំណាយក្នុងដំណើរការដោះស្រាយដីធ្លីជាបន្ទុករបស់រាជរដ្ឋាភិបាល ។

**ប្រការ ៤** : សមាជិកនៃគណៈកម្មការអន្តរក្រសួងនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។ ប្រធានគណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធមកចូលរួមប្រជុំតាមការចាំបាច់ ។

**ប្រការ ៥ :** ក្នុងទិសដៅធានាការពារផលប្រយោជន៍សាធារណៈ គណៈកម្មការនេះមានសិទ្ធិចាត់វិធានការសមស្រប ទាំងឡាយ ដោយយោងតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីអនុវត្តអនុក្រឹត្យ និងលិខិតបទដ្ឋានផ្សេងទៀតដែលទាក់ទងការងារដោះស្រាយគោលនយោបាយដីធ្លី ក្នុងបរិវេណដូចមានបញ្ជាក់ក្នុងប្លង់ភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យ ដែលមានផ្ទៃក្រឡាសរុប ៦៨២ ហិកតា ។

**ប្រការ ៦:** បណ្តាក្រសួង ស្ថាប័ន អង្គភាព អាជ្ញាធរពាក់ព័ន្ធ ត្រូវចូលរួមសហប្រតិបត្តិការឱ្យបានពេញលេញជាមួយ គណៈកម្មការនេះ សំដៅធ្វើការដោះស្រាយគោលនយោបាយជាមួយប្រជាពលរដ្ឋឱ្យបានទទួលលទ្ធផលវិជ្ជមានឆាប់រហ័ស ។

**ប្រការ ៧:** អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល ប្រធាននាយកដ្ឋានរដ្ឋបាល គ្រប់ស្ថាប័ន អង្គភាពដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញៈ ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៦*

**ឧបនាយករដ្ឋមន្ត្រី**

**សុខ អាន**

***កន្លែងទទួល :***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ក្រសួងមហាផ្ទៃ*
- *ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៧*
- *រាជកិច្ច* ✓
- *ឯកសារ-កាលប្បវត្តិ*